
Kids of Destiny®
Reaching the Next Generation
www.kidsofdestiny.org

## 2.07 **កំណើតម៉ូសេ**

បន្ទាប់ពីប្រាំពីរឆ្នាំនៃភោគផលល្អនៅស្រុកអេហ្ស៊ីប ពេលដែលមានអាហារសំបូរហូរហៀរ ហើយក៏បានចូលមកដល់នៅប្រាំពីរឆ្នាំដ៏លំបាកនៅពេលដែលមិនមានស្បៀងអាហារគ្រប់គ្រាន់។ យ៉ូសែបបានរៀបចំផែនការយ៉ាងល្អប៉ុន្តែប្រាក់របស់ប្រជាជនក៏អស់ហើយ។ ប្រជាជននាំគ្នាមកជួបលោកយ៉ូសែបជំរាបថា៖ «យើងត្រូវការស្បៀងអាហារតែយើងគ្មានប្រាក់ទិញទេ។ យ៉ូសែបបានប្រាប់ពួកគេថាពួកគេអាចប្ដូរយកចំណីអាហារដោយដោះដូរសត្វចិញ្ចឹមរបស់ពួកគេ។ ហើយពួកគេក៏ធ្វើដូច្នេះទៅ។ មួយឆ្នាំកន្លងផុតទៅ ប្រជាជននាំគ្នាមកជួបលោកយ៉ូសែបពោលថា៖ «យើងត្រូវការម្ហូបអាហារតែឥឡូវយើងគ្មានអ្វីទិញទេ។ អ្នកអាចទិញយើង និងដីរបស់យើង ហើយយើងនឹងធ្វើជាអ្នកបម្រើរបស់លោក" ។ ជាលទ្ធផលលោកយ៉ូសែបក៏បានទិញដី និងទិញប្រជាជនតែម្ដង។ គាត់បានបង្ហាញពួកគេពីរបៀបដាំគ្រាប់ពូជ និងប្រមូលផល។ ពួកគេអាចទុកផលខ្លះសម្រាប់ធ្វើជាអាហារ។ នៅសល់នឹងត្រូវបញ្ជូនទៅស្ដេចផារ៉ោន។ ក្រុមគ្រួសាររបស់យ៉ូសែបបានផ្លាស់ទីលំនៅពីស្រុកកាណានមកនៅជាមួយយ៉ូសែប ហើយយ៉ូសែបក៏មើលថែរក្សាពួកគេ។ ពួកគេបានរស់នៅក្នុងទឹកដីកូសែន។ ពួកគេបានរស់នៅទីនោះរហូតឆ្លងកាត់គ្រោះទុរ្ភិក្ស។ គ្រួសាររបស់ពួកគេកាន់តែច្រើនឡើងច្រើនឡើង។ ជាលទ្ធផលក៏មានក្រុមគ្រួសារជាច្រើនរបស់យ៉ាកុបនៅលើទឹកដីនោះ។ ពួកគេត្រូវបានគេហៅថាហេប្រឺ។ ច្រើនឆ្នាំបានកន្លងផុតទៅ។ ស្ដេចដ៏ឃោរឃៅនិងអាក្រក់បានឡើងជាស្ដេចផារ៉ោននៅស្រុកអេស៊ីប។ គាត់មិនស្គាល់លោកយ៉ូសែប និងគ្រួសាររបស់គាត់ទេ។ ស្ដេចថ្មីនេះមិនចូលចិត្តប្រជាជនហេប្រឺឡើយ។ គាត់ខ្លាចថានឹងមានកូនចៅហេប្រឺកាន់តែច្រើនកើតមកទៀត។ គាត់ខ្លាចជនជាតិហេប្រឺកាន់តែខ្លាំងពូកែជាងជនជាតិអេស៊ីប។ ព្រះចៅផារ៉ោនមានផែនការសម្លាប់ក្មេងប្រុសទាំងអស់ដែលកើតពីស្ដ្រីជនជាតិហេប្រឺ។ ទ្រង់បានប្រាប់ស្ដ្រីអោយបោះចោលកូនប្រុសរបស់ពួកគេចូលទៅក្នុងទន្លេក្រោយពេលសំរាលកូន។ មានម្ដាយជាច្រើនដែលសោកសៅយ៉ាងខ្លាំងដោយសារតែរឿងនេះ។ ម្ដាយម្នាក់បានសំរេចចិត្តរក្សាកូនរបស់នាងទុកដោយសម្ងាត់។ នាងបានធ្វើកន្ត្រកហើយដាក់កូននៅក្នុងនោះ។ នាងបានដាក់វានៅក្នុងគុម្ពោតនៅក្នុងទឹក។ កន្ត្រកបានចាប់ផ្ដើមអណ្ដែតនៅតាមដងទន្លេ។ នៅគ្រានោះបុត្រីរបស់ព្រះចៅផារ៉ោនបានចុះទៅមាត់ទន្លេជាមួយអ្នកបំរើរបស់ទ្រង់។ ទ្រង់បានឃើញទារកអណ្ដែតលើទឹកហើយរំភើបយ៉ាងខ្លាំង។ ទ្រង់បានយកកន្ត្រកចេញពីទឹកហើយឃើញទារកហេប្រឺនៅខាងក្នុង។ ទ្រង់ចង់រក្សាទុក! ពេលនោះមានបងស្រីម្នាក់របស់ទារកដែលបានដើរតាមប្អូនប្រុសរបស់នាងនៅពេលដែលគាត់អណ្ដែតចុះទៅក្នុងទឹកទន្លេនោះ។ នាងប្រញាប់ប្រញាល់ទៅរកបុត្រីរបស់ព្រះចៅផារ៉ោនហើយពោលថា៖ «តើទ្រង់ត្រូវការមេដោះសំរាប់ទារកទេ? បុត្រីរបស់ផារ៉ោនឆ្លើយថា៖ «ចាស! ទៅរកស្ដ្រីជនជាតិហេប្រឺម្នាក់មកដើម្បីបំបៅទារកនេះ។ ខ្ញុំនឹងជួលនាង។ ភ្លាមៗនោះក្មេងស្រីបានរត់ទៅរកម្ដាយរបស់នាងផ្ទាល់! ដូច្នេះម្ដាយនាងអាចធ្វើជាមេដោះសម្រាប់កូនរបស់គាត់ទៅ!

ដូច្នេះទារកជនជាតិហេប្រឺតូចនេះបានក្លាយជាកូនរបស់បុត្រីផារ៉ោន។ នាងបានដាក់ឈ្មោះអោយគាត់ថាម៉ូសេ ដែលមានន័យថា "ទាញចេញ" ពីព្រោះនាងបានទាញគាត់ចេញពីទឹក។ គាត់នឹងធំឡើងដើម្បីនាំប្រជាជនហេប្រឺត្រឡប់ទៅស្រុកកាណានវិញ។ **(និក្ខមនំ ២)**

## 2.07 កំណើតលោកម៉ូសេ - សេចក្តីណែនាំសម្រាប់គ្រូបង្រៀន

## កំណត់សំគាល់

១) យ៉ូសែបបានរៀបចំផែនការយ៉ាងល្អ សម្រាប់ទុរ្ភិក្សប្រាំពីរឆ្នាំ ។ ប្រជាជនបានមករកគាត់ ដើម្បីទិញស្បៀងដែលបានរក្សាទុក ។ ប៉ុន្មានឆ្នាំកន្លងផុតទៅ ប្រជាជនបានអស់ប្រាក់ទិញស្បៀងអាហារ ។ ពួកគេបានប្រាប់ដល់លោកយ៉ូសែបថា ពួកគេនឹងទិញអាហារដោយដោះដូរសត្វរបស់ពួកគេ ។

២) ពេលវេលាកន្លងផុតទៅប្រជាជនត្រូវការប្រាក់ម្តងទៀត ។ លើកនេះលោកយ៉ូសែបបានទិញប្រជាជន និងដីរបស់ពួកគេ ។ ឥឡូវពួកគេនឹងក្លាយជាខ្ញុំ ទាសកររបស់ស្តេចផារ៉ោន ។

៣) លោកយ៉ូសែប និងក្រុមគ្រួសាររបស់គាត់ត្រូវបានគេហៅថាជនជាតិហេព្រើរ ។ លោកយ៉ូសែបបាននាំប្រជាជនរបស់គាត់ទៅស្រុកអេស៊ីព្ទ ដើម្បីមើលថែរក្សាពួកគេ ។ មានមនុស្សជាច្រើននៅក្នុងគ្រួសាររបស់គាត់ ។ ជាច្រើនឆ្នាំកន្លងផុតទៅ មានជនជាតិហេព្រើរជាច្រើនបានកើតមក ។

៤) ស្តេចផារ៉ោនថ្មីដែលអាក្រក់ បានក្លាយជាអ្នកគ្រប់គ្រងស្រុកអេស៊ីព្ទ ។ គាត់ខ្លាចប្រជាជនហេព្រើរកាន់តែខ្លាំងពូកែជាងប្រជាជនអេហ្ស៊ីព្ទ ។ គាត់បានព្យាយាមសម្លាប់ក្មេងប្រុសជនជាតិហេព្រើរទាំងអស់ ។

៥) ទារកម្នាក់ត្រូវបានសង្គ្រោះ ។ ម្តាយរបស់គាត់បានដាក់គាត់នៅក្នុងកន្ត្រក ហើយបណ្តែតវាចុះទៅក្នុងទឹកទន្លេ ។

៦) កូនស្រីរបស់ស្តេចផារ៉ោនបានរកឃើញទារកនោះ ហើយបានទុកគាត់ ។ នាងដាក់ឈ្មោះទារកថាម៉ូសេ។

**សំណួរ:**

១) នៅពេលដែលប្រជាជនអស់ប្រាក់ តើពួកគេដោះដូរអ្វីសម្រាប់ទិញស្បៀង?

២) នៅពេលប្រជាជនអស់ប្រាក់ និងសត្វ តើពួកគេបានដោះដូរអ្វីទៀតសម្រាប់ទិញស្បៀង?

៣) តើប្រជាជនរបស់យ៉ូសែបត្រូវបានគេហៅថាជាជនជាតិអ្វី?

៤) ស្តេចផារ៉ោនខ្លាចអ្វី?

៥) តើគាត់បានព្យាយាមធ្វើអ្វី?

៦) បុត្រីរបស់ស្តេចផារ៉ោនបានរកឃើញអ្វីនៅក្នុងទឹក?

៧) បុត្រីរបស់ស្តេចផារ៉ោនដាក់ឈ្មោះកូននោះថាអ្វី?

**ចម្លើយ:**

១) ប្រជាជនបានទិញស្បៀងអាហារដោយដោះដូរសត្វរបស់ពួកគេ។

២) ប្រជាជនបានប្រាប់លោកយ៉ូសែបថា គាត់អាចយកដីរបស់ពួកគេ ហើយយកពួកគេធ្វើជាទាសករ ដើម្បីទិញស្បៀងអាហារ ។

៣) ប្រជាជនរបស់លោកយ៉ូសែប ត្រូវបានគេហៅថាជនជាតិហេព្រើរ ។

៤) ស្តេចផារ៉ោនខ្លាចប្រជាជនហេព្រើរ នឹងមានអំណាចជាងជនជាតិអេស៊ីព្ទ ។

៥) ស្តេចផារ៉ោនព្យាយាមសម្លាប់ក្មេងប្រុសទាំងអស់ ។

៦) កូនស្រីផារ៉ោន បានរកឃើញទារកជនជាតិហេព្រើរម្នាក់ នៅក្នុងទឹក ។

៧) នាងដាក់ឈ្មោះកូននោះថា ម៉ូសេ ។



Kids of Destiny®
Reaching the Next Generation

www.kidsofdestiny.org